# តើអ្វីជាការប្រើអង់ទីករម៉ូណូក្លូន?

ប្រសិនបើអ្នកប្រឈមនឹងហានិភ័យដែលអាចឈឺធ្ងន់ដោយសារជំងឺ COVID-19 ហើយបានធ្វើតេស្តឃើញវិជ្ជមានជំងឺ COVID-19 ឬបានប៉ះពាល់ផ្ទាល់ជាមួយនឹងបុគ្គលដែលបានធ្វើតេស្តឃើញវិជ្ជមាន អ្នកគួរតែពិចារណាប្រើអង់ទីករម៉ូណូក្លូន (mAb)។ អ្នកអាចមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានការព្យាបាលជំងឺ COVID-19 ដោយប្រើ mAb អាស្រ័យលើអាយុ ប្រវត្តិសុខភាព និងរយៈពេលដែលអ្នកចេញរោគសញ្ញា។

ការប្រើ mAb អាចរារាំងវីរុសដែលបង្កជំងឺ COVID-19 មិនឱ្យចូលក្នុងកោសិកា និងកាត់បន្ថយចំនួនវីរុសក្នុងរាងកាយរបស់អ្នក។ នេះមានន័យថា អ្នកអាចមានរោគសញ្ញាក្នុងកម្រិតស្រាលជាង និងអាចកាត់បន្ថយភាគរយដែលត្រូវសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ។

ការប្រើ mAb អាចជួយបុគ្គលដែល៖

- ប្រឈមនឹងហានិភ័យខ្ពស់ដែលអាចនឹងមានរោគសញ្ញាធ្ងន់ធ្ងរជាង **និង**
- បានធ្វើតេស្តឃើញវិជ្ជមានជំងឺ COVID-19 ដោយមានរោគសញ្ញារយៈពេល 7 ថ្ងៃចុះក្រោម **ឬ**
- បានប៉ះពាល់ផ្ទាល់ជាមួយនឹងបុគ្គលដែលធ្វើតេស្តឃើញវិជ្ជមានថ្មីៗនេះ

## • តើអ្វីជាអង់ទីករម៉ូណូក្លូន?

ជាធម្មតា រាងកាយរបស់អ្នកផលិតអង់ទីករដើម្បីប្រឆាំងនឹងការចម្លង។ ទោះយ៉ាងណា រាងកាយរបស់អ្នកប្រហែលជាគ្មានអង់ទីករដែលស្គាល់វីរុសប្រភេទថ្មី (ឬថ្មី) ដូចជា SARS-CoV-2 ជាវីរុសដែលបង្កជំងឺ COVID-19 ទេ។ អង់ទីករម៉ូណូក្លូន ឬ mAb ត្រូវបានផលិតក្នុងមន្ទីរពិសោធន៍ដើម្បីប្រយុទ្ធប្រឆាំងនឹងការចម្លងជាក់លាក់ (ក្នុងករណីនេះគឺវីរុស SARS-CoV-2) និងផ្តល់ឱ្យអ្នកដោយផ្ទាល់តាមរយៈការចាក់ថ្នាំ។ ការប្រើ mAb អាចជួយបាន ប្រសិនបើអ្នកប្រឈមនឹងហានិភ័យខ្ពស់ដែលអាចមានរោគសញ្ញាធ្ងន់ធ្ងរ ឬសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

ការប្រើ mAb សម្រាប់ជំងឺ COVID-19 គឺខុសគ្នាពីវ៉ាក់សាំងជំងឺ COVID-19។ វ៉ាក់សាំងជួយជំរុញប្រតិកម្មឆ្លើយតបនៃប្រព័ន្ធភាពស៊ាំពីធម្មជាតិរបស់រាងកាយអ្នក ប៉ុន្តែវាអាចចំណាយពេលច្រើនសប្តាហ៍ទើបផលិតអង់ទីករគ្រប់គ្រាន់ដើម្បីប្រឆាំងនឹងវីរុស។ ដូច្នេះប្រសិនបើអ្នកឆ្លងវីរុស នោះការប្រើ mAb ជួយផ្តល់អង់ទីករឱ្យរាងកាយរបស់អ្នក ដែលវាត្រូវការដើម្បីការពារខ្លួន។ ការប្រើ mAb មិនអាចជំនួសតម្រូវការសម្រាប់ប្រព័ន្ធភាពស៊ាំពីវ៉ាក់សាំងបានទេ ប៉ុន្តែវាអាចជួយអ្នកបាន ប្រសិនបើអ្នកប្រឈមនឹងហានិភ័យដែលអាចមានជំងឺ COVID-19 ធ្ងន់ធ្ងរ។

## • តើការប្រើអង់ទីករម៉ូណូក្លូនអាចធ្វើឱ្យខ្ញុំឈឺដែរទេ?

ការប្រើអង់ទីករមិនមានវីរុសណាមួយដែលនៅរស់ទេ ដូច្នេះវាគ្មានហានិភ័យដែលអ្នកនឹងឆ្លងជំងឺ COVID-19 ដោយសារការប្រើ mAb ឡើយ។ ទោះយ៉ាងណា ការប្រើអង់ទីករអាចមានផលប៉ះពាល់។ សូមពិគ្រោះជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអំពីផលប៉ះពាល់ដែលអាចមាន និងអ្វីដែលត្រូវធ្វើប្រសិនបើអ្នករងផលប៉ះពាល់ទាំងនោះ។

## • ចុះបើខ្ញុំគ្មានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីប្រើអង់ទីករម៉ូណូក្លូន?

អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចសម្រេចថាអ្នកគ្មានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីប្រើ mAb ឬអត់។ អាចមានមូលហេតុច្រើនសម្រាប់ករណីនេះ។ អ្នកប្រហែលជាមិនបំពេញតាមលក្ខខណ្ឌទាំងអស់

ឬអ្នកប្រហែលជាមានបញ្ហាសុខភាពដែលធ្វើឱ្យអ្នកមិនអាចប្រើ mAb បាន។ សាកសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអំពីជម្រើសប្រើថ្នាំផ្សេងទៀត។

## • តើខ្ញុំអាចទទួលបានអង់ទីករម៉ូណូក្លូនតាមវិធីណា?

ជំហានទី 1៖ ធ្វើតេស្តឃើញវិជ្ជមានជំងឺ COVID-19 និងមានរោគសញ្ញារយៈពេល 7 ថ្ងៃចុះក្រោម។

ជំហានទី 2៖ ទទួលបានការណែនាំបន្តពីអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

ជំហានទី 3៖ ស្វែងរកមណ្ឌលចាក់ថ្នាំដែលមានផ្តល់សេវា។

ដើម្បីទទួលបាន mAb អ្នកគួរតែណែនាំបន្តឱ្យប្រើដោយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក និងណែនាំទៅទីតាំងចាក់ថ្នាំដែលមានផ្តល់សេវា។ **ប្រសិនបើអ្នកគ្មានអ្នកផ្តល់សេវាថែទាំសុខភាពទេ** សូមទូរសព្ទទៅ Combat COVID Monoclonal Antibodies Call Center (មជ្ឈមណ្ឌលហៅទូរសព្ទផ្នែកអង់ទីករម៉ូណូក្លូនប្រឆាំងនឹងជំងឺ COVID) តាមរយៈលេខ 1-877-332-6585 ដើម្បីឱ្យដឹងថាត្រូវពិគ្រោះជាមួយនរណាអំពីរោគសញ្ញា និងការប្រើអង់ទីករ។

Washington State Department of Health

DOH 825-031 March 2022 Khmer
ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។
អតិថិជនស្តាប់មិនឮ ឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay)
ឬផ្ញើអ៊ីមែលទៅ mailto:ecivil.rights@doh.wa.gov។